# កម្មវិធីសម្ពោធឱ្យប្រើប្រាស់គេហទំព័រទិន្នន័យ Cambodia Urban Database

## សេចក្តីសង្ខេប

ខណៈដែលទីក្រុងជាច្រើននៅកម្ពុជា មានការរីកចម្រើន និងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ទិន្នន័យ អំពីទីក្រុងដែលមានគុណភាពខ្ពស់ គឺមានសារៈសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវ និងការតាក់តែងគោលនយោបាយឱ្យបានល្អ។ ដូច្នេះ ការបង្កើតប្រព័ន្ធទិន្នន័យទីក្រុងមួយ ដែលអនុញ្ញាតឱ្យសាធារណជនទូទៅអាចប្រើប្រាស់បានយ៉ាងទូលំទូលាយគឺជារឿងចាំបាច់។ ដើម្បីសម្រេចគោលដៅនេះ **មជ្ឈមណ្ឌលខេមរសិក្សា** (CKS) បានដាក់ឱ្យប្រើប្រាស់គេហទំព័រទិន្នន័យ Cambodia Urban Database ដែលប្រមូលផ្តុំដោយទិន្នន័យ និងឯកសារស្រាវជ្រាវជាច្រើន និងសម្ភារបែបពាក់ព័ន្ធនឹងប្រធានបទទីក្រុងនៅកម្ពុជា។

កម្មវិធីនេះនឹងណែនាំអំពីទិដ្ឋភាពទូទៅនៃគេហទំព័រទិន្នន័យថ្មីមួយនេះ រួមទាំងរបាយការណ៍ អត្ថបទទិនានុប្បវត្តិ កម្រងទិន្នន័យស្ថិតិ ផែនការមេនៃទីក្រុង ផែនទី កម្រងរូបភាព និងឯកសារពាក់ព័ន្ធផ្សេងៗជាច្រើនទៀត ដែលត្រូវបានចងក្រងតាមលំដាប់លំដោយ។ តាមរយៈការពិភាក្សាជាមួយក្រុមអ្នកស្រាវជ្រាវអំពីទីក្រុង យើងខ្ញុំនឹងលើកឡើងពីវិធីសាស្ត្រសំខាន់ៗដែលសិស្ស និស្សិត អ្នកស្រាវជ្រាវ និងអ្នកចូលរួមផ្សេងៗអាចទទួលបានអត្ថប្រយោជន៍ពីគេហទំព័រទិន្នន័យនេះ ហើយអាចចូលរួមចំណែកក្នុងការកសាងសមត្ថភាពលើការសិក្សាអំពីទីក្រុងនៅកម្ពុជា។ កម្មវិធីនេះនឹងត្រូវរៀបចំឡើងជាភាសាខ្មែរ ព្រមទាំងអនុញ្ញាតឱ្យអ្នកចូលរួមអាចសួរសំណួរបន្ថែមនៅវគ្គសំណួរ-ចម្លើយ ។

## វាគ្មិន:

**បណ្ឌិត យ៉េន យ៉ាត** បានបញ្ចប់ថ្នាក់បណ្ឌិត ជំនាញគ្រប់គ្រងធនធានដីធ្លី ពីសាកលវិទ្យាល័យភូគព្ភសាស្ត្រ (China University of Geosciences-Wuhan)នៅឆ្នាំ២០១៧ និងបានបញ្ចប់ថ្នាក់បណ្ឌិតមួយទៀតជំនាញរដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃប្រទេសចិន (University of Science and Technology of China) នៅឆ្នាំ២០១៨។ បន្ទាប់មក គាត់បានបញ្ចប់ការស្រាវជ្រាវ ថ្នាក់ក្រោយបណ្ឌិត(Postdoc) ជំនាញគោលនយោបាយទីក្រុង ពីសាកលវិទ្យាល័យប៉េកាំង (Peking University) នៅឆ្នាំ២០២០។ គាត់ក៏ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលខេមរសិក្សាផងដែរ។ គាត់បានធ្វើការសិក្សាស្រាវជ្រាវ និងស្ទង់មតិជាច្រើនសារ ដោយប្រើវិធីសាស្ត្របែបគុណវិស័យ និងបរិមាណវិស័យ ក៏ដូចជារៀបចំវិធីសាស្ត្រស្រាវជ្រាវ ការបង្កើតកម្រងសំណួរស្ទង់មតិ ការត្រួតពិនិត្យលើការប្រមូលទិន្នន័យ ការវិភាគនិងបកប្រែទិន្នន័យ សរសេររបាយការណ៍ និងការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវមួយ

ចំនួនក្នុងទិនានុប្បវត្តិអន្តរជាតិល្បីៗ។ មុនពេលចូលរួមធ្វើការងារស្រាវជ្រាវជាមួយមជ្ឈមណ្ឌលខេមរ-សិក្សា គាត់ធ្លាប់ជាមន្ត្រីរាជការមួយរូបនៃក្រសួងអប់រំ យុវជន និងកីឡាពីឆ្នាំ ២០០៦-២០០១១។ គាត់ក៏ធ្លាប់ធ្វើជាអ្នកពិគ្រោះយោបល់ឱ្យអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ក.ជ.ទ) និងអង្គការទស្សនៈពិភពលោកអន្តរជាតិនៃកម្ពុជាផងដែរ៕